ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សារលិខិតជូនពរ

**សូមគោរពជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**និង សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

សម្ដេចអគ្គមហាសេនាបតីតេជោ និង សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានៃខួប ៤៥ឆ្នាំ ចំណងអាពាហ៍ពិពាហ៍របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់ នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក មេត្តាប្រោសប្រទានសព្វសាធុការពរ បវរថ្លៃថ្លាមហាប្រសើរ ជូន **សម្ដេចតេជោ** និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** សូមសមប្រកបដោយសុខភាពល្អបរិបូណ៍ បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីបន្តដឹកនាំព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់សុខសន្តិភាព វឌ្ឍនភាព និងភាពសម្បូររុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំសូមសម្ដែងនូវសេចក្ដីគោរពដឹងគុណដ៏ស្មោះអស់ពីដួងចិត្តចំពោះគំរូវីរភាពដ៏ឆ្នើមរបស់ **សម្ដេច** ដែលបានរួមចំណែកតស៊ូរំដោះប្រទេសជាតិ ស្វះស្វែងរកសន្តិភាព បង្រួបបង្រួមជាតិ កសាង និងអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនដូចបច្ចុប្បន្ន។ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេច** បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ត្រចះត្រចង់ជាបន្តបន្ទាប់ ថែរក្សាបាននូវសុខសន្តិភាព អធិបតេយ្យភាព បូរណភាពទឹកដីដ៏រឹងមាំ ឯកភាពជាតិ ស្ថិរភាពជាតិ និងការរីកចម្រើនជឿនលឿនលើគ្រប់វិស័យ ព្រមទាំងទទួលបាននូវកិត្យានុភាពដ៏ស័ក្តិសម ទាំងក្នុងក្របខណ្ឌតំបន់ និងលើឆាកអន្តរជាតិ។

ជាថ្មីម្ដងទៀត ស្ថិតក្នុងឱកាសដ៏វិសេសវិសាលនេះផងដែរ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ សូមប្រសិទ្ធពរជ័យសិរីសួស្តី ជ័យមង្គល វិបុលសុខបវរមហាប្រសើរថ្លៃថ្លាជូន **សម្ដេចអគ្គមហាសេនាបតីតេជោ** និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រធីតា និង ចៅប្រុស ចៅស្រី សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា មេត្តាទទួលនូវគារវកិច្ច និងស្មោះស្ម័គ្រដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ៕៚

ថ្ងៃចន្ទ ៦រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែមករា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**